**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំកម្មវិធីសម្រស់ឯកវាយនភណ្ឌឆ្នាំ២០១៦

ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣០ **ទិវាពលកម្មអន្តរជាតិ ១ ឧសភា** និងដើម្បីបង្កើតឱកាសសប្បាយរីករាយដល់បងប្អូនកម្មករ-កម្មការិនី ដែលកំពុងបម្រើការងារក្នុងវិស័យឧស្សាហកម្ម ផ្នែកវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ស្ថានីយទូរទស្សន៍PNN អង្គការវិជ្ជាជីវៈ និងដៃគូពាក់ព័ន្ធនានា រៀបចំ **កម្មវិធីសម្រស់ឯកវាយនភណ្ឌឆ្នាំ២០១៦** នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦។ ដំណើរការចុះឈ្មោះ និងកម្មវិធីប្រឡងមានដូចខាងក្រោម៖

**១-ការចែក និងទទួលពាក្យ៖** ចាប់ពី **ថ្ងៃទី១៩ ដល់ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦**

**២-ទីកន្លែងទទួលពាក្យ៖** ទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង (បេក្ខជន-បេក្ខនារីអាចទាញយកពាក្យស្នើសុំប្រឡងតាមរយៈគេហទំព័រ www.mlvt.gov.kh ឬ https://www.facebook.com/mlvt.gov.kh/)។

**៣-អំពីការជ្រើសរើស៖ វគ្គទី១** នឹងប្រព្រឹត្តទៅនៅថ្ងៃទី**០៣ ខែមេសា ឆ្នាំ២០១៦** នៅ៖

- **មណ្ឌលរាជធានីភ្នំពេញ៖ បេក្ខជន១០រូប បេក្ខនារី១០រូប** លើបេក្ខជនសរុប ដែលបានដាក់ពាក្យនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- **មណ្ឌលខេត្តព្រះសីហនុ៖ បេក្ខជន០៥រូប បេក្ខនារី០៥រូប** លើបេក្ខជនសរុប ដែលបានដាក់ពាក្យនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ
- **មណ្ឌលខេត្តស្វាយរៀង៖ បេក្ខជន០៥រូប បេក្ខនារី០៥រូប** លើបេក្ខជនសរុប ដែលបានដាក់ពាក្យនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង

**៤-កម្មវិធីប្រឡងផ្តាច់ព្រ័ត្រ៖ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ១៧:០០នាទី នៅស្ថានីយទូរទស្សន៍PNN (ផ្សាយផ្ទាល់)** ដែលស្ថិតនៅភូមិព្រែកតាវ៉ាត់ សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

**៥-លក្ខណៈសម្បត្តិសម្រាប់បេក្ខជនមាន៖**

- ជាកម្មករ-កម្មការិនី កំពុងធ្វើការងារយ៉ាងតិចបីខែក្នុងវិស័យឧស្សាហកម្ម ផ្នែកវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង ។
- មានកម្ពស់ចាប់ពី ១.៦២ម សម្រាប់បេក្ខជន និង១.៥៨ម សម្រាប់បេក្ខនារី និងមានអាយុចាប់ពី ១៨ឆ្នាំ ដល់៣០ឆ្នាំ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង ៖**

- លោក និន វណ្ណៈ ទូរសព្ទលេខ ០១២ ៩១៦ ០០៩ (រាជធានីភ្នំពេញ និងបណ្តាខេត្តនានា )
- លោក យ៉ូវ ខេមរា ទូរសព្ទលេខ ០៩៣ ៩៩៩ ១៦៨ (ខេត្តព្រះសីហនុ)
- លោក ហាស់ ប៊ុនធី ទូរសព្ទលេខ ០១២ ៣៩១ ២១៧ (ខេត្តស្វាយរៀង)

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិត មេត្តាជ្រាបជាព័ត៌មាន។

*រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦*

**បញ្ជាក់៖**
ការមកទទួល និងដាក់ពាក្យរបស់បេក្ខជន បេក្ខនារី មិនត្រូវឱ្យប៉ះពាល់ដល់សង្វាក់ផលិតកម្មឡើយ។

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ពាក្យសុំចុះឈ្មោះជាបេក្ខជន-បេក្ខនារីក្នុងកម្មវិធីសម្រស់ឯកទាយនគណ្ឌឆ្នាំ២០១៦

១. គោត្តនាមនិងនាមៈ..............................ជាអក្សរឡាតាំង..............................ទូរស័ព្ទផ្ទាល់ខ្លួន....................
ទូរស័ព្ទអ្នកជិតស្និទ្ធ...................................Facebook.....................................ភេទ........................................
សញ្ជាតិ..................កម្ពស់............ទម្ងន់...........
ទំហំទាំងបី(សម្រាប់បេក្ខនារី)ៈចង្កេះ.............ទ្រូង...............ត្រគៀក..............

២. ថ្ងៃខែឆ្នាំកំណើតៈ ថ្ងៃទី.............ខែ...................ឆ្នាំ...................អាយុ...........ឆ្នាំ

៣. ទីកន្លែងកំណើតៈ ផ្ទះលេខ............ក្រុមទី.............ភូមិ..............................ឃុំ/សង្កាត់.................................
ស្រុក/ខណ្ឌ.....................ខេត្ត/រាជធានី..........................................................................................

៤. ទីលំនៅបច្ចុប្បន្នៈផ្ទះលេខ..........ក្រុមទី...........ភូមិ................ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ................
.......................................................ខេត្ត/រាជធានី..........................................................................

៥. ស្ថានភាពគ្រួសារៈ ☐នៅលីវ ☐មានប្តី/ប្រពន្ធ

៦. កម្រិតវប្បធម៌...................................................................................................................................

៧ ថ្ងៃខែឆ្នាំចូលធ្វើការនៅរោងចក្របច្ចុប្បន្នៈថ្ងៃ........... ខែ............ ឆ្នាំ........ឈ្មោះរោងចក្រ..................................
អត្តលេខ......................លេខទូរស័ព្ទ.....................ការងារផ្នែក.....................តួនាទី.......................................
ជំនាញការងារ.......................................................................................................................................

៨. ប្រវត្តិ និងបទពិសោធន៍ការងារកន្លងមក ធ្លាប់ការងារអ្វីខ្លះ?.........................................................................

៩. ស្នាដៃការងារៈ ☐ធ្លាប់ទទួលលិខិតប័ណ្ណសរសើរ ☐គ្មាន ☐ផ្សេងៗៈ..............................................

១០. តើអ្នកធ្លាប់ទទួលបានការអប់រំ ផ្សព្វផ្សាយ ច្បាប់ស្តីពីការងារអ្វីខ្លះ?..........................................................
.............................................................................................................................................................

១១. តើអ្នកធ្លាប់បានទទួលការបណ្តុះបណ្តាលអ្វីខ្លះពីរោងចក្រ?.........................................................................

១២. តើអ្នកចេះជំនាញសិល្បៈអ្វីខ្លះ?.............................................................................................................

១៣. ជំនាញភាសាបរទេសៈ.............................................................................................................................

១៤. ចំណង់ចំណូលចិត្តៈ...................................................................................................................................

១៥. បន្ទាប់ពីជាប់ជ័យលាភីសម្រស់ឯកប្រចាំឆ្នាំ២០១៦ តើអ្នកនឹងធ្វើអ្វីដើម្បីអភិវឌ្ឍន៍ការងាររបស់អ្នក?......................
.............................................................................................................................................................

១៦. តើអ្នកនឹងជួយការងារសង្គមអ្វីខ្លះ?.........................................................................................................
.............................................................................................................................................................
.............................................................................................................................................................

................ថ្ងៃទី ខែ ឆ្នាំ២០១៦

ស្នាមមេដៃស្តាំ/ហត្ថលេខា

**បញ្ជាក់ៈ**-បេក្ខជន-បេក្ខនារីសូមភ្ជាប់នូវរូបថតមួយជំហរខ្លួនមួយសន្លឹក និងថតចម្លងបណ្ណសម្គាល់បម្រើការងារនៅរោងចក្រ ០១ច្បាប់

- ទីតាំងដាក់ពាក្យ នៅទីស្តីការក្រសួង ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុឬ មន្ទីរ ក.បខេត្តស្វាយរៀង